**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៩៨ **នាមនាមប្រជារាស្ត្រខ្មែរ**

ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០០០ តុលាការកំពូល

សាលដីកា បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៧ ខែ មីនាឆ្នាំ ២០០១

លេខ ៤៨ ដោយមានសមាសភាពដូចតទៅ :

ចុះថ្ងៃទី ២៧ខែ មិនា ឆ្នាំ២០០១

១- ឯកឧត្តម **ឌិត មុន្ទី** ជាប្រធាន

២- លោក ប៉ែន ស៊ុន ជាចៅក្រម

៣- លោក វៀល មួន ជាចៅក្រម

៤- លោក ប្រាក់ គឹមសាន ជាចៅក្រម

៥- លោក គង់ ភិរុណ ជាចៅក្រម របាយការណ៍

ក្រឡាបញ្ជី

លោក ឡេង វុធ

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៦៩ "ង" ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤០១ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ហេង អ៊ុយហុក ( តតីយជន ) ភេទប្រុស អាយុ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរ ប្រធានក្រុមហ៊ុនហុកខ្មែរហ្វ្រារិក ទីលំនៅផ្ទះលេខ ២១ A ផ្លូវបារាំង សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ និង អ្នកស្រី ហេង វូច ជាសមាជិក ក្រុមហ៊ុនហុកខ្មែរហ្វ្រារិច ។

មានមេធាវី លោក ចុង អៀវហេង

ម្ចាស់បណ្តឹងសាទុក្ខ ឈ្មោះ ស្រី សុខសម្បត្តិ ភេទស្រី ( តំណាងឱ្យក្រុមហ៊ុនហុកខ្មែរ ហ្វ្រារិច ) ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ ឡាវ មុណ្ណី ភេទប្រុស អាយុ ៤១ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃ ក្រុមទី ៦ មណ្ឌល២ សង្កាត់ ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ សេក សារី ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ក្រុមទី៧ មណ្ឌល២ សង្កាត់៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

បានផ្ទេរសិទ្ធិឱ្យលោក លឹម ហាក់ ។

<u>អំពី វិវាទ</u> :    ប្ដឹងសុំរំលាយកិច្ចសន្យាលក់-ទិញ និង សុំបដិសេធប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ។

បានឃើញបណ្ដឹងសាទុក្ខលេខ ៣០០ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០០ របស់លោក ហេង អ៊ុយហុក ប្ដឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ ៦៩ " ង " ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុច នៃ សេចក្ដីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៩៨ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី ១០-៨-៩៤ របស់ឈ្មោះ ឡាវ មុណ្ឌី និង ឈ្មោះ សេក-សាវី បានប្ដឹងសុំរំលាយកិច្ចសន្យាទិញ-លក់ ដីធ្លី រវាងពួកខ្លួន និងឈ្មោះ ស្រី សុខសម្បត្តិ ដោយអាងហេតុថា : កាលពីថ្ងៃទី ១២-៣-៩៤ ឈ្មោះ ស្រី សុខសម្បត្តិ តំណាងឱ្យលោក ហេង អ៊ុយហុក និង អ្នកស្រី ហេង វួច បានទិញដីធ្លីពីខ្លួន ដោយសន្យាថា នឹងប្រគល់ប្រាក់ឱ្យខ្លួនគ្រប់ចំនួននាថ្ងៃទី ២០-៥-៩៤ ។ បន្ទាប់មកឈ្មោះនេះ ក៏សុំពន្យាពេលចំនួន ០៥ ថ្ងៃ បន្តទៀត គឺផុតនៅថ្ងៃទី ២៥-៥-៩៤ ។ ផ្ទុយទៅវិញរហូតមកដល់សព្វថ្ងៃនេះ ឈ្មោះខាងលើ ពុំព្រមប្រគល់ប្រាក់ឱ្យពួកខ្លួន តាមការសន្យានៅឡើយ ។ ហេតុនេះពួកខ្លួនសំណូមពរសុំរំលាយកិច្ចសន្យាទិញ-លក់ដី និង បដិសេធប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីចំនួន ១៣ ប័ណ្ណ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ១០ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ របស់តុលាការក្រុងព្រះសីហនុ សំរេចចំពោះមុខដើមចោទ កំបាំងមុខតំណាងចុងចម្លើយ និង តតីយជន ដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ :

១-    ទទួលពាក្យបណ្ដឹងរបស់ ឡាវ មុណ្ឌី និង លោក សេក សាវី " ដើមចោទ " ចុះថ្ងៃទី ១០-៨-៩៤ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-    រំលាយកិច្ចសន្យាលក់ដី ចុះថ្ងៃទី ១២-៣-៩៤ របស់គូភាគីចោលជាអសារបង់ ។

៣-    បដិសេធប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីលេខ C1 0432 , C10433 , C10434 ,C1 0435 C1 0436 , C1 0437 , C1 0438 , C1 0439 , C1 0440 , C1 0441 , C1 0442 , C1 0443 , C1 0444 ចុះថ្ងៃទី ១៣-១២-៩៣ ដែលមានលោក ហេង អ៊ុយហុក និង អ្នកស្រី ហេង វួច ជាម្ចាស់កម្មសិទ្ធិ ចោលជាអសារបង់តម្រូវឱ្យប្រគល់ដីទាំងអស់ ដែលមានក្នុងប័ណ្ណទាំង១៣ នេះ ឱ្យទៅលោក ឡាវ-មុណ្ឌី និង លោក សេក សាវី គ្រប់គ្រងជាម្ចាស់កម្មសិទ្ធិវិញ ចាប់តាំងពីថ្ងៃសាលក្រមក្លាយជាសាលក្រមស្ថាពរ ។

៤-    ឱ្យលោក ឡាវ មុណ្ឌី និង លោក សេក សាវី ប្រគល់ប្រាក់ចំនួន ១.៣៤៤.០០០បាត និង ការប្រាក់ ៥ភាគរយ ក្នុង១ឆ្នាំ គិតចាប់តាំងពីថ្ងៃទទួលប្រាក់រហូតដល់ថ្ងៃសងប្រាក់ ឱ្យទៅលោក ហេង-អ៊ុយហុក និង អ្នកស្រី ហេង វួច ។

៥-    ឱ្យលោក ស្រី សុខសម្បត្តិ បង់ប្រាក់ប្រដាប់ក្ដីគឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្លឹងចំនួន ១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ចំនួន៥.០០០៛ សរុប ៧.០០០៛ តែប្រាក់

នេះ ត្រូវបានកាត់យកពីប្រាក់៧.០០០៛ ដែលដើមចោទ បានបង់ទុករួចហើយ កាលបើហួសឧទ្ធរណ៍ត្រូវបង្គាប់ឱ្យចុងចម្លើយសងប្រាក់ ៧.០០០៛ នេះ ទៅដើមចោទវិញ និង ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រចំនួនមួយភាគរយលើតម្លៃដីជាក់ស្តែងនូវដីទំហំ ៦២ ហិកតា ៦១អា បន្ថែមទៀត តែត្រូវដាក់ចូលថវិការដ្ឋចំនួន ៨០ ភាគរយ និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងកម្ពុជាចំនួន ២០ ភាគរយ តែប្រាក់នេះ ត្រូវឱ្យដើមចោទបង់ទុកជាមុនដែរ ទើបបង្គាប់ឱ្យចុងចម្លើយសងទៅដើមចោទជាក្រោយវិញ ។

សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខតំណាងចុងចម្លើយ និង តតិយជនរបស់ចុងចម្លើយ ទុកសិទ្ធិឱ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់ ។

បានឃើញ បណ្តឹងទាស់ លេខ ០៩ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៧ របស់លោក ហេង អ៊ុយហុក ប្តឹងមិនសុខចិត្ត នឹងសាលក្រមលេខ ១០ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ១៩៩៧ របស់តុលាការក្រុងព្រះសីហនុ លើសេចក្តីសំរេចទាំងមូល ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ៥១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៧ របស់តុលាការក្រុងព្រះសីហនុ សំរេចចំពោះមុខដើមចោទ កំបាំងមុខតតិយជន ជាលើកទី២ ដែលមានខ្លឹមសារនៃ សេចក្តីសំរេច ដូចតទៅ :

១- ទទួលពាក្យបណ្តឹងទាស់របស់តតិយជន លោក ហេង អ៊ុយហុក និង អ្នកស្រី ហេង វួច ចុះថ្ងៃទី ០៥-៣-៩៧ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- តំកល់សាលក្រមកំបាំងមុខលេខ ១០ ចុះថ្ងៃទី ២៤-០២-៩៧ ចាត់ទុកជាបានការពេញទាំងមូល ។

៣- សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខតតិយជនជាលើកទី២ តែចាត់ទុកជាចំពោះមុខ ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ២ខែ តាមច្បាប់កំណត់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ០៩ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៨ របស់លោក ហេង អ៊ុយហុក ប្តឹងមិនសុខចិត្ត នឹងសាលក្រមលេខ ៥១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៧ របស់តុលាការក្រុងព្រះសីហនុ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៦ " គ " ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខចុងបណ្តឹងឧទ្ធរណ៍ កំបាំងមុខដើមបណ្តឹងឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៧-០៤-១៩៩៨ របស់ឈ្មោះហេង អ៊ុយហុក និង ឈ្មោះ ហេង វួច តតិយជនចុងចម្លើយ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៥១ ចុះថ្ងៃទី ១៧-០៦-១៩៩៧ របស់តុលាការក្រុងព្រះសីហនុ ទុកជាបានការពេញទាំងមូល ។

៣- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹង

២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០៛ និង លើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។

៤- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ និង តតិយជនចុងចម្លើយ បើកផ្លូវប្ដឹងតវ៉ា ក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្ដឹងទាស់លេខ ២៤ ចុះថ្ងៃទី ០១ ខែ មិនា ឆ្នាំ ២០០០ របស់លោក ហេង អ៊ុយហុក ( ពាក្យបណ្ដឹងទាស់ចុះថ្ងៃទី ២៥-០២-២០០០ )ដែលមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៦ " ត " ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៦៩ " ង " ចុះថ្ងៃទី ១៦ ខែ មិនា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខ លឹម ហាក់ កំបាំងមុខឈ្មោះ សុខ សម្បត្តិ តតិយជនឈ្មោះ ហេង អ៊ុយហុក និង ហេង វួច និង មេធាវីការពារចុងចម្លើយ ឈ្មោះ ចុង អៀវហេង ដែលមានខ្លឹមសារ នៃ សេចក្ដីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹងទាស់ ចុះថ្ងៃទី ០១-០៣-២០០០ របស់ឈ្មោះ ហេង អ៊ុយហុក ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយផ្ទុយនឹង គតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ ១៦ " ត " ចុះថ្ងៃទី ២០-០១-២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការ ប៉ុន្តែលើកលែងចំណុចការប្រាក់គប្បីបដិសេធចោល ។

៣- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខឈ្មោះលឹម ហាក់ កំបាំងមុខឈ្មោះ សុខ សម្បត្តិ តតិយជនឈ្មោះ ហេង អ៊ុយហុក និងហេង វួច និង មេធាវីការពារចុងចម្លើយឈ្មោះ ចុង អៀវហេង តែចាត់ទុកជាចំពោះមុខ ។

បានឃើញបណ្ដឹងសាទុក្ខ លេខ ៣០០ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០០ របស់លោក ហេង អ៊ុយហុក ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ ៦៩ " ង " ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី ១៧-០៩-២០០០ របស់ឈ្មោះ ហេង អ៊ុយហុក

បានឃើញសារណាតប ចុះថ្ងៃទី ១៦-១១-២០០០ របស់ឈ្មោះ លឹម ហាក់ តំណាងឱ្យឈ្មោះ ឡាវ មុណ្ណី , សេក សារី និង ភូ ហេង " ជាម្ចាស់លក់ដី " ។

- បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ ថា :

- បណ្ដឹងសាទុក្ខរបស់តតិយជន ស្ថិតនៅក្នុងកំណត់ច្បាប់ គប្បី លើកយករឿងនេះ មកពិនិត្យពិចារណា ។

សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

ក្រឡាបញ្ជីអានសារណារបស់លោក ហេង អ៊ុយហុក

បានស្តាប់ចម្លើយរបស់ឈ្មោះ លឹម ហាក់ " ជាអ្នកទទួលសិទ្ធិពីដើមចោទ " ពេលជំនុំជំរះឆ្លើយបញ្ជាក់ថា : ចំពោះពាក្យដែលថា លោក ហេង អ៊ុយហុក បានប្រគល់ប្រាក់ដល់ទៅ មួយលានបីសែននោះ ជាការមិនពិតទេ ព្រោះគ្មានឯកសារឯណាបញ្ជាក់ថា លោក ហេង អ៊ុយហុក បានសងប្រាក់ឡើយ ។ បើគេសងម្តេចគេមិនសងនៅពេលនោះទៅ បែជាគេសុំសងនៅពេលនេះវិញ ។

ខ្លួនមិនទទួលស្គាល់ថា លោក ហេង អ៊ុយហុក ប្រគល់ប្រាក់មួយលានបីសែនទេ គឺទទួលតែមួយលានមួយសែនប៉ុណ្ណោះ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់តតីយជន និង ចម្លើយដោះសាររបស់តំណាងដើមចោទ .
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣០០ ចុះថ្ងៃទី ០៦-០៧-២០០០ របស់ឈ្មោះ ហេង អ៊ុយហុក ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើកឡើងនេះ មកជំនុំជំរះ បានតាមមាត្រា ១៤ នៃច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ សំរេចតម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៥១ ចុះថ្ងៃទី ១៧-៦-៩៧ របស់តុលាការក្រុងព្រះសីហនុ នោះ គឺជាការពុំត្រឹមត្រូវឡើយពីព្រោះថា :

សាលាឧទ្ធរណ៍ពុំបានស៊ើបអង្កេត និង ពិចារណាទៅលើចំនួនទឹកប្រាក់ ដែលអ្នកលក់បានទទួលពីអ្នកទិញ មានចំនួន ប៉ុន្មានពិតប្រាកដ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ សំរេចលុបចោលការប្រាក់ ៥% ក្នុងមួយឆ្នាំនោះ គឺជាការសំរេចទៅលើសាលក្រមដែលចូលជាស្ថាពរលើភាគី ឡាវ មុណ្ណី និង សេក សាវី ទៅហើយ ។

- យល់ឃើញថា ចុងចម្លើយ និង តតីយជន បានធ្វើសារណា ជូនមកតុលាការហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូល ជំនុំជំរះរឿងនេះ កំបាំងមុខចុងចម្លើយ និង តតីយជន ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៦៩ ចុះថ្ងៃទី ១១-៥-២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីកំបាំងមុខតំណាងដើមចោទ កំបាំងមុខចុងចម្លើយ

និង តតីយជន ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ ៣០០ ចុះថ្ងៃទី ០៦-០៧-២០០០ របស់ឈ្មោះ ហេង អ៊ុយហុក

ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីកា លេខ ៦៩ " ង " ចុះថ្ងៃទី ១១-៥-២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២៩៨ ចុះថ្ងៃទី ០៨-៨-២០០០ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះ ជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រ៛០០ ដែលលោក ឡាវ មុណ្ឌី បង់រួចហើយគឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹង ចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយក្នុងការប្រគល់ដីកាកោះចំនួន ១៥.០០០ រៀល សរុប ១៩.០០០ រៀល ។

៥- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ២៧ ខែ មីនាឆ្នាំ២០០១ ។